សំណុំឆឹកឃ្លុំ ៣/២ (មេសា ២០០២)៖ ២៥-៣៣



# កូនស្រីពិការពិត តែចិត្តមិនពិការឡើយ

*អ្នកស្រី សួន នាង*

កណ្តាលរាត្រីដ៏សែនស្ងាត់ មានសំលេង ង៉ា ង៉ា បន្លឺចេញពីផ្ទះឈើមួយខ្នង ។ ង៉ា ង៉ា ជាសំលេងទារិកាម្នាក់ដែលទើបនឹងបើកភ្នែកទទួលពន្លឺនៃសេចក្តីស្រឡាញ់ពីឪពុកម្តាយ ទទួលភាពកក់ក្តៅពីដៃជីដូនជីតា និងទទួលធាតុក្តៅត្រជាក់ពីព្រះអាទិត្យ និងព្រះច័ន្ទ ។ សំលេង ង៉ា ង៉ា ចង់ប្រាប់ថានាងឃ្លាន នាងភ័យ ព្រោះពីពេលនេះទៅនាងត្រូវប្រឹងប្រែងដោយខ្លួនឯង ។ គឺនាងត្រូវដកដង្ហើមខ្លួនឯង ត្រូវប្រឹងជញ្ជក់ទឹកដោះម្តាយហើយលេបខ្លួនឯង ។

មនុស្សទាំងអស់នៅក្នុងគ្រួសារញញឹម សប្បាយរីករាយ ព្រោះបានសមាជិកាថ្មីម្នាក់ទៀត ។ ជីដូនជីតាស្រឡាញ់ចៅស្រីណាស់ ហើយបានដាក់ឈ្មោះថា *សៀវ លី* ។ គ្មានអ្នកណាម្នាក់នឹកបារម្ភពីអ្វីដែលនឹងត្រូវធ្លាក់មកលើគ្រួសារនេះឡើយ ។

មួយឆ្នាំបានកន្លងទៅ... ។

ថ្ងៃមួយនោះបុគ្គលិកពេទ្យភូមិដើរចាក់ថ្នាំការពារជំងឺ៦មុខឲ្យក្មេងៗ ។ ម្ដាយ *សៀវ លី* រួសរាន់អញ្ជើញពេទ្យចាក់ថ្នាំឲ្យកូន ។ ពេទ្យសួរថា កូនអ្នកមានក្ដៅខ្លួនទេ? គាត់ឆ្លើយថា អត់ក្ដៅខ្លួនទេ ។ គ្រូពេទ្យចាក់ថ្នាំរួចទើបគាត់នឹកឃើញថា ពីយប់មិញគាត់បានឲ្យកូនញ៉ាំថ្នាំប៉ារ៉ា ។ គាត់គ្រាន់តែនឹកឃើញមួយភ្លែតក៏ភ្លេចទៅវិញភ្លាម ព្រោះរវល់លួងលោមកូនឲ្យបាត់យំ ។

យប់នោះ *សៀវ លី* ក្ដៅខ្លួនខ្លាំងណាស់ កន្ត្រាក់ដៃ កន្ត្រាក់ជើង ម្ដាយ *សៀវ លី* ឲ្យកូនញ៉ាំប៉ារ៉ាទៀត តាមការណែនាំរបស់គ្រូពេទ្យដែលបានចាក់ថ្នាំពីព្រឹក ។

ព្រឹកឡើង ម្ដាយ សៀវ លី មានការបារម្ភខ្លាំងជាងពីយប់ ព្រោះក្រៅពីកំដៅមិនចុះ ដៃជើងកូនគាត់ហាក់ដូចជាពិបាកកំរើកខុសពីពេលធម្មតា ។ ញាតិជិតខាងខ្លះឲ្យយោបល់ថាគួរតែនាំកូនទៅមន្ទីរពេទ្យ ប៉ុន្តែខ្លះថា មិនអីទេ ចាក់ថ្នាំការពារធ្វើទុក្ខអីចឹងហើយ ។ មួយអាទិត្យកន្លងទៅ ជំងឺ *សៀវ លី*នៅតែដដែល ដូច្នេះគាត់ក៏សំរេចចិត្តយក *សៀវ លី* ទៅមន្ទីរពេទ្យ ។ គាត់បានសំរាកនៅមន្ទីរពេទ្យបីសប្ដាហ៍ ។ *សៀវ លី* បាត់ក្ដៅខ្លួនហើយ តែអាការៈដៃជើងខ្លួនប្រាណធ្វើឲ្យគាត់អស់សង្ឃឹម ។ មាត់វៀច ម្រាមដៃស្ដាំក្ដាប់យ៉ាងតឹង ម្រាមឆ្វេងលាត ហើយប្រឹងឡើងរឹង ។ ប្រអប់ជើងរមួលខ្ទេចូលក្នុង ឯម្រាមជើងកាច់ចុះក្រោម ។

ទុក្ខសោកបានគ្របដណ្ដប់គ្រួសារដ៏អភ័ព្វនេះ ។ ម្ដាយឪពុក ជីដូនជីតា តែងតែរត់ទៅរកគ្រូគ្រប់ទីកន្លែងដែលគេប្រាប់ និងបន់ស្រន់ដូនតាសែនអារក្សអ្នកតាគ្រប់ពេលដែលហោរាណែនាំ ។

ពេលវេលាចេះតែកន្លងទៅ ។

នៅពេលដែល *សៀវ លី* អាយុ៦ឆ្នាំ នាងអាចអង្គុយបាន ប៉ុន្តែមិននឹងល្អ ហើយអាចនិយាយបាន ប៉ុន្តែអ្នកក្រៅគ្រួសារស្ដាប់មិនយល់ទេ ។ *សៀវ*

*លី* មិនអាចដើរបានឡើយ ។ ឪពុកម្ដាយចាប់ផ្ដើមអស់សង្ឃឹមមែនទែន គាត់ឈប់រកគ្រូ ហើយឈប់ជឿ បន់ដូនបន់តា គាត់គិតតែពីរកស៊ីវិញម្ដង ។

ថ្វីត្បិតតែ *សៀវ លី* ដើរមិនរួច ប៉ុន្តែរូបរាងកាយចេះតែរីកដុះដាល ធំធាត់ទៅតាមអាយុកាលដែរ ។ ឥឡូវនេះ *សៀវ លី* អាយុ១២ឆ្នាំហើយ ។ នាងតែងរំកិលចុះតាមកាំជណ្ដើរឲ្យគេជួយលើកដាក់លើអង្រឹងនៅក្រោមផ្ទះ។ ដោយដៃជើងនាងរឹងក្រញ៉ឹងក្រញង់ នាងធ្លាក់ពីលើអង្រឹង ឬទោងញយដង។ ការធ្លាក់ញយដងនេះ ជាវិធីសំងាត់ដែលជំរុញឲ្យនាងប្រឹងងើបឈរដោយខ្លួនឯង ។ នៅអាយុ១៣ឆ្នាំ *សៀវ លី* អាចងើបឈរដោយខ្លួនឯងបានយ៉ាងត្រដាបត្រដួស ប៉ុន្តែមិនអាចឈានដើរឡើយ ។

ថ្ងៃមួយនោះ ជាថ្ងៃដែលព្រះជាម្ចាស់ប្រទានពរឲ្យ *សៀវ លី* ។ មានស្ត្រីចំណាស់ម្នាក់ មានរបរជាគ្រូព្យាបាលជំងឺបន្តិចបន្តួចតាមបែបបុរាណ បានឃើញ *សៀវ លី* ហើយបានសុំយកនាងទៅព្យាបាលនៅផ្ទះគាត់ ។ ឪពុកម្ដាយមិនមានសង្ឃឹមអ្វីទេលើលោកយាយម្នាក់នោះ ប៉ុន្តែគាត់ចង់សាកល្បងមើល ។ ដូច្នេះគាត់ក៏សំរេចចិត្តនាំ *សៀវ លី* ទៅផ្ទះលោកយាយ ។ លោកយាយមិនអនុញ្ញាតឲ្យមានក្រុមគ្រួសារណាម្នាក់នៅជាមួយ *សៀវ លី* ឡើយ ឪពុកម្ដាយស្រក់ទឹកភ្នែកអាណិតកូនពេលចាកចេញត្រលប់ទៅផ្ទះវិញ ព្រោះ *សៀវ លី* ត្រូវរស់នៅជាមួយលោកយាយក្នុងខួមជរា ។

លោកយាយចងឬស្សីមួយដើមភ្ជាប់ទៅនឹងដើមស្លា ដើម្បីធ្វើស្ពា រាល់ថ្ងៃ លោកយាយឲ្យ *សៀវ លី* ក្រោកពីយប់ដើម្បីហាត់ប្រាណ ។ លំហាត់ប្រាណគឺត្រូវតោងឈរ ។ ទោះបី *សៀវ លី* ដួលប៉ុន្មានដងក៏ដោយ ក៏លោកយាយមិនខ្វល់ដែរ គឺដាច់ខាតត្រូវតែប្រឹងតោងឈរឲ្យទាល់តែបាន និងខំតោងដើរទៅមុខ ។ ក្រៅពីហាត់ប្រាណមិនឲ្យទំនេរទេ ត្រូវធ្វើការបន្តិចបន្តួចជានិច្ច ដូចជា បាចអង្ករឲ្យមាន់ លាងចានឆ្នាំង ដាំបាយ បោចស្មៅ ។

រស់នៅឆ្ងាយពីគ្រួសារ៦ខែហើយ *សៀវ លី* នឹកផ្ទះណាស់ នឹកម្ហូបឆ្ងាញ់ នឹកភាពរីករាយជួបជុំក្រុមគ្រួសារ និងនឹកភាពកក់ក្តៅ ការថ្នាក់ថ្នមពីឪពុកម្តាយ ជីដូនជីតា ។ នាងស្រមៃឃើញថា ពេលនេះនៅផ្ទះនាង នាងកំពុងជិះអង្រឹង មើលទូរទស្សន៍ ឬស្តាប់ម៉ាញ៉េ ។ ប៉ុន្តែនាងក៏សប្បាយនឹងធម្មជាតិពិតៗនៅផ្ទះលោកយាយដែរ ។ នាងបានឃើញគោ ក្របី ឃើញគេធ្វើស្រែពីព្រោះម្តងម្កាល លោកយាយបររទេះដាក់ *សៀវ លី* យកទៅស្រែជាមួយគាត់ ។ នៅភ្នំពេញជាមួយឪពុកម្តាយ បរិបូរណ៍ទៅដោយភាពប្រណិតមែន ប៉ុន្តែនាងមិនដែលបានចេញក្រៅរបងផ្ទះឡើយ ។ ជួនកាល ពេលមានភ្ញៀវមកផ្ទះនាង នាងពួនក្នុងបន្ទប់ ។

ខែទីមួយ ក្នុងការស្នាក់នៅផ្ទះលោកយាយ ឪពុកម្តាយទៅមើលនាងរាល់អាទិត្យ ។ ខែបន្ទាប់ៗមកពីរ ឬបីអាទិត្យទើបមានបងប្អូន ឬជីដូនជីតាមកលេងម្តង ។ ការប្រែប្រួលនេះ ប្រហែលជាក្រុមគ្រួសារមានការទុកចិត្តទាំងស្រុងលើលោកយាយ ឬក៏ពួកគាត់រវល់នឹងការរកស៊ីមមាញឹកពេកក៏មិនដឹង ។

នៅខែទី៦នេះ *សៀវ លី* មានការរីកចំរើនយ៉ាងច្រើនខាងចលនា គឺនាងអាចដើបឈរបានរហ័សជាងមុន និងអាចឈានជើងដើរបានបួនប្រាំជំហានដោយមិនបាច់តោងស្ន ។ ចាត់ទុកថាជាជោគជ័យដ៏ធំចំពោះវិធីសាស្ត្រដឹកនាំព្យាបាលរបស់លោកយាយ ។ មនុស្សទាំងអស់សប្បាយរីករាយណាស់ ។ គេគិតថាព្រះជាម្ចាស់បានប្រទានពន្លឺជីវិតឲ្យ *សៀវ លី* ហើយ ។

សូមលោកអ្នកអានជួយថាមើល តើអ្នកណាសប្បាយចិត្តជាងគេក្នុងចំណោមមនុស្សទាំងអស់នោះ?

ក្រុមគ្រួសារសំរេចចិត្តយក *សៀវ លី* ត្រឡប់ទៅផ្ទះវិញ ។ ឥឡូវនេះ *សៀវ លី* ហាក់ដូចជានិស្សិតដែលទើបប្រឡងចេញពីមហាវិទ្យាល័យ ។ នាងមិនអង្គុយយោលទោង យោលអង្រឹងដូចមុនទៀតទេ ។ នាងចង់ចាំជានិច្ច

ពាក្យណែនាំចុងក្រោយរបស់លោកយាយ និងការហ្វឹកហាត់ដ៏តឹងរ៉ឹងរយៈពេល៦ខែ ។ ឥឡូវនេះនាងអាយុ១៨ឆ្នាំហើយ នាងអាចជួយការងារក្នុងផ្ទះបានច្រើន ។ ការងារដែលនាងធ្វើសុទ្ធតែស្អាតភ្លឹង ចានឆ្នាំងដែលនាងដុសលាងភ្លឺឆ្លុះមុខបាន ។ បើបោសផ្ទះវិញ សូម្បីស្រមោចដ៏តូចក៏រត់គេចមិនរួចដែរ ។

កាលពីមុនមនុស្សចាស់ៗក្នុងគ្រួសារគ្រាន់តែអាណិត *សៀវ លី* ព្រោះនាងពិការ ប៉ុន្តែឥឡូវនេះ ពួកគាត់បានថែមទឹកចិត្តមួយតំណក់ធំទៀតគឺការស្រឡាញ់ និងសរសើរពេញចិត្ត ។ *សៀវ លី* ក្លាយជាកោសិកាមួយមានប្រយោជន៍សំរាប់គ្រួសារហើយ ។

នៅឆ្នាំ១៩៩៨ ព្រះជាម្ចាស់បានបញ្ជូន "ក្រុមបងប្រុសបេសកកម្ម៉ារីស" (MARIST MISSION AUSTRALIA) មកកម្ពុជា ។ ព្រះអង្គប្រគល់ភារកិច្ចដល់ក្រុមនេះឲ្យបើកសាលារៀនមួយសំរាប់កុមារពិការ ។

ឱកាសមាសសំរាប់ *សៀវ លី* មកដល់ហើយ ។

ថ្ងៃទី ២២ មិថុនា ឆ្នាំ ១៩៩៨ ជាថ្ងៃបើកបវេសនកាលរបស់សាលានេះ ។ ក្នុងចំណោមសិស្សពិការទាំង៤៧នាក់ យើងឃើញវត្តមានរបស់ *សៀវ លី* ម្នាក់ដែរ ។ ឪពុកម្តាយប្រកបដោយទឹកមុខស្រស់ស្រាយបំផុត បានដើរអមជួយទប់ *សៀវ លី* ។ នាងដើរពិបាកណាស់ នាងមិនអាចបញ្ឈរលើចលនានាងបានទេ ។ នាងអត់ពាក់ស្បែកជើងទេ ។ មិនមែននាងគ្មានលទ្ធភាពទិញទេ ប៉ុន្តែមកពីនាងពាក់មិនជាប់ ។ កាលនោះក្នុងវ័យ១៨ឆ្នាំ *សៀវ លី* ជាកុមារីពិតៗ មិនធាត់ ហើយក៏មិនស្គមកំព្រឹងដែរ ។ (រៀននៅសាលាបានតែកន្លះឆ្នាំ *សៀវ លី* ស្ទុះធំប្លែក) ។

នៅសាលាពីរថ្ងៃដំបូងយើងមិនទាន់រៀនអក្សរទេ យើងនាំក្មេងៗលេងល្បែងខ្លះៗ សំណេះសំណាលអំពីគ្រួសារគេខ្លះ ណែនាំឲ្យ ស្គាល់គ្នា ណែនាំពីវិន័យសាលា ពីរបៀបស្លៀកពាក់ឯកសណ្ឋាន និងពីការកកើតនៃសាលា ។ *សៀវ លី* ញញឹមជានិច្ច ។

ក្នុងចំណោមសិស្សទាំងអស់ មានសិស្ស៥នាក់ពិបាកកាន់ប៊ិច ឬដីស ហើយក្នុង៥នាក់នោះ មាន *សៀវ លី* ដែរ ។ មានសិស្សម្នាក់សរសេរនឹងជើង ម្នាក់ទៀតមិនអាចសរសេរលើសៀវភៅ ត្រូវមានក្ដារខៀនធំមួយឲ្យគេហាត់សរសេរដោយប្រើដីសខ្លាតធំជិតប៉ុនមេជើង ។ (លុះក្រោយមកប៉ុន្មានខែ សិស្សនេះអាចសរសេរលើសៀវភៅបានដោយប្រើប៊ិចដងធំ)។ អក្សរពួកគេធំៗមិនល្អទេ ប៉ុន្តែយើងសប្បាយ យើងមើលបាន ។ ឯអក្សរ*សៀវ លី*វិញ តូចៗល្អិតៗ មានសក់ មានជើងច្បាស់គួរសម ។ *សៀវ លី* ខំរៀនណាស់ ។ គ្រប់លំហាត់នៅផ្ទះតែងតែធ្វើបានយ៉ាងស្អាត ក្នុងមួយថ្ងៃ *សៀវ លី* ត្រូវហាត់ប្រាណមួយម៉ោង គឺហាត់ធ្វើចលនាពន្លាត សរសៃជើង ដៃ ត្រគាក និងហាត់ដើរតាមគំនូសបន្ទាត់ ។ នាងខំណាស់មិនដែលតួញត្អែរ ឬមកយឺតពេលទេ។ នៅសាលា *សៀវ លី*រីករាយជានិច្ច រហូតនាងនិយាយថា "ខ្ញុំមិនចង់ឲ្យដល់ថ្ងៃសៅរ៍ អាទិត្យទេ ខ្ញុំនៅផ្ទះនឹកសាលាណាស់" ។ អ្វីដែលធ្វើឲ្យ *សៀវ លី* សប្បាយបិទមាត់មិនជិតនោះ គឺអ្នកគ្រូបានបង្រៀននាងឲ្យចេះពាក់ស្បែកជើង ស្បែក ជើងដែលជាជំរើសសំរាប់នាង គឺស្បែកជើងបាត់តា ។ ដំបូងទំលាប់ពាក់តែស្រោមជើងទេ ក្រោយមកពេលនាងស៊ាំនឹងស្រោមជើងហើយ យើងណែនាំឲ្យពាក់ស្បែកជើង ប៉ុន្តែពាក់តែនៅពេលអង្គុយរៀនប៉ុណ្ណោះ ។ សប្ដាហ៍ដំបូងអ្នកគ្រូពាក់ឲ្យ សប្ដាហ៍បន្ទាប់នាងរៀនពាក់ដោយខ្លួនឯង ។ ពេលនាងចេះពាក់ខ្លួនឯងច្បាស់ហើយ ទើបយើងអនុញ្ញាតឲ្យនាងពាក់ស្បែកជើងដើរ ។ សិស្សរួមថ្នាក់ជួយលើកទឹកចិត្តដោយប្រការផ្សេងៗ ពេលឃើញ *សៀវ លី* ពាក់ស្បែកជើងដើរ ។ នាងអៀនតិចៗ ប៉ុន្តែសប្បាយចិត្តណាស់ ពីព្រោះ១៨ឆ្នាំហើយនាងមិនដែលពាក់ស្បែកជើងទេ ។ នេះជាជោគជ័យមួយក្នុងជីវិតរបស់នាង ។

ថ្ងៃមួយអ្នកគ្រូបាននាំសិស្សទៅលេងភ្នំប្រសិទ្ធ ។ ក្រោយពេលញ៉ាំបាយថ្ងៃត្រង់ហើយ សិស្សភាគច្រើនអង្គុយជជែកគ្នាលេងក្រោមម្លប់ឈើ ។

ពេលនោះ *សៀវ លី* មិនអង្គុយទេ នាងដើរម្នាក់ឯងបាត់មួយសន្ទុះធំ ។ អ្នកគ្រូតាមរក អ្នកគ្រូភ័យព្រោះបាត់ *សៀវ លី* ប៉ុន្តែ *សៀវ លី* និយាយថា "សប្បាយណាស់អ្នកគ្រូ ខ្ញុំមិនដែលបានដើរច្រើនដូចថ្ងៃនេះទេ ខ្ញុំសុំទោសដែលធ្វើឲ្យអ្នកគ្រូភ័យ" ។ អ្នកគ្រូមិនខឹងទេ រំភើបនឹងសំដីសិស្សស៊ីងស្រក់ទឹកភ្នែក ។ អ្នកគ្រូអោបសិស្សហើយនិយាយថា "អ្នកគ្រូខ្លាចកូនដួលម្នាក់ឯង" ។ *សៀវ លី* ឆ្លើយថា "មិនអីទេអ្នកគ្រូ បើដួល ខ្ញុំអាចងើបបាន" ។

សាលាដែល *សៀវ លី* រៀន ឈ្មោះ សាលា "ឡាវ៉ាឡា" ។ នាងរៀនបាន២ឆ្នាំ នាងអាចអាន សរសេរ និងអាចគិតលេខបាន ។ នាងជាក្មេងឆ្លាតដឹងខុសត្រូវណាស់ មិនដែលធ្វើឲ្យមានការលំបាកដល់មិត្តភក្តិ ឬគ្រូឡើយ ។ ពេលសរសេរនាងលំបាកណាស់ ពីព្រោះដៃវាចេះតែ កន្ត្រាក់ញ័រឥតឈប់ ។ នាងប្រើពេលយូរណាស់ដើម្បីសរសេរ ។ ការតស៊ូក្នុងការសរសេរ និងការហាត់ប្រាណរបស់នាង ជាគំរូដ៏វិសេសមួយ ដែលមិនងាយមានអ្នកធ្វើបានដូចនាងឡើយ ។

នៅឆ្នាំ២០០០ នាងមានជំងឺគ្រុនពោះវៀន ។ ក្រោយមកនាងជាធម្មតាវិញ ប៉ុន្តែមិនដឹងជាយ៉ាងណា ឪពុកម្ដាយមិនអនុញ្ញាតឲ្យនាងមករៀនឡើយ។ អ្នកគ្រូបានទៅលេងដើម្បីសួរសុខទុក្ខនាង ។ នាងស្គមច្រើន គេងនៅកន្ទេលជាប់ មិនញ៉ាំ មិននិយាយស្តី ។ ជីដូននិយាយថា ពេលយប់នាងគេងមិនលក់ទេ ។ ពេលជួបអ្នកគ្រូ នាងញញឹមយ៉ាងជូរចត់ មើលមុខអ្នកគ្រូមួយភ្លែតហើយងាកមុខចេញ នាងយំ ។ អ្នកគ្រូក៏ មិនចេញស្តី អង្អែលដៃសិស្ស ហើយលាម្ចាស់ផ្ទះមកវិញទាំងអួលដើមក ។

ពីរឆ្នាំហើយយើងខានជួប*សៀវ លី* ។ យើងនៅតែនឹកនាង ។ តើនាងនឹកពួកយើង ឬទេ? ។

សូមព្រះជាម្ចាស់ប្រទានពរសុខសាន្ត និងសេចក្តីសង្ឃឹមដល់នាង ។

## សរុបសេចក្តី

រាងកាយពិការពិតជាលំបាកមែនហើយសំរាប់សាមីខ្លួនផ្ទាល់ ប៉ុន្តែយើងមិនត្រូវគិតថាមិនបានការសោះនោះទេ ។ មើលចុះ *សៀវ លី* អាចរៀនបាន អាចសរសេរបាន អាចដើរបាន និងអាចធ្វើកិច្ចការផ្ទះបានគ្រប់យ៉ាងដូចមនុស្សធម្មតាដែរ ។ ឪពុកម្តាយដែលមានកូនពិការតែងតែមានបំណងចំបងមួយគឺ ចង់ឲ្យកូនដើរបាន ។ សូមមើលចុះ មនុស្សខ្លះដើរ បាន និយាយបាន មើលឃើញ តែអត់មានសមត្ថភាពដូច *សៀវ លី* ទេ មូលហេតុមកពីខ្វះការតស៊ូប្រឹងប្រែងដើម្បីបង្កើនសមត្ថភាព ។



*សៀវ លី និង អ្នកគ្រូរបស់គេ សួន នាង*

មានកត្តាសំខាន់បីយ៉ាង ដើម្បីជួយបង្កើនសមត្ថភាព គឺ៖

១- មានទឹកចិត្តតស៊ូយកឈ្នះលើការលំបាកក្នុងការធ្វើចលនា។

២- មានទឹកចិត្តជម្នះលើពាក្យចាស់គំរិល ដែលតែងពោលថា ភាពពិការជាឧបសគ្គនៃជីវិត ឬថា អ្នកពិការធ្វើអ្វីមិនកើត ។

៣- មានការគាំទ្រ និង លើកទឹកចិត្តពីមជ្ឈដ្ឋានខាងក្រៅ មាន មិត្តភក្តិ ឪពុកម្តាយ និង អង្គការនានា ។

ករណី *សៀវ លី* បង្ហាញឲ្យយើងឃើញថា ការហាត់ប្រាណពិតជាមានប្រយោជន៍សំខាន់ណាស់ក្នុងការសំរួលចលនា ។

*សៀវ លី* មិនដូចពាក្យស្លោកមួយដែលពោលថា "ដេកផ្សំដួល រមួលផ្សំគ្រិច" នោះឡើយ ។

ព្រះជាម្ចាស់បានបើកផ្លូវឲ្យនាង បានប្រទានពរឲ្យនាង ។ នាងបានទទួលពរព្រះអង្គ ហើយបានប្រតិបត្តិតាមយ៉ាងអស់ពីចិត្ត ។

HONEYCOMB 3/2 (April 2002): 34–40



# A Determined Disabled Daughter

*SOUN Neang*

The night's silence is broken by the sound of *Gnar Gnar* streaming from a wooden house. *Gnar Gnar* is the sound a child makes who has just opened her eyes to see the light of her parents' love, to receive warmth from her grandparents, and to welcome hot and cold from the sun and the moon. The sound of *Gnar Gnar* means that she is hungry, afraid because from now she has to make a serious effort by herself. She needs to breathe and has to suck the mother's breast and swallow by herself.

All the people in the family are very happy because they have a new member. The grandparents love their grandchild very much and name her Siew Ly. Nobody is worried about what is going to happen to this family.

And now one year passes by.

One day, a commune hospital staff came to immunize the children against six illnesses. Siew Ly's mother invited him to inject her child immediately. The doctor asked, "Does your child have a fever?" She replied, "No, she has not." But after the injection, the mother remembered that the previous night she had given paracetamol to her child. She only briefly remembered, and then quickly forgot again because she needed to comfort her child and calm her crying.

That night Siew Ly developed a serious fever, and her arms and legs began to convulse. Siew Ly's mother gave paracetamol to her again as her doctor had instructed.

In the morning Siew Ly's mother's concern grew because the child's temperature had not come down, and her arms and legs could hardly move. Some of the neighbors suggested that she take Siew Ly to the hospital, while others counseled, "Never mind, this is usual for children after receiving the injection to protect against the six illnesses." In a week's time, Siew Ly's condition worsened, so her mother decided to bring her to the hospital. She stayed there for three weeks. Siew Ly's temperature improved, but her arms, legs, and body deteriored, making her mother very hopeless. The child's mouth became twisted, her right fingers clenched into a fist, while her left hand stretched out straight and hard. Her feet were twisted in and her toes turned down.

Sadness covered this family. The parents and grandparents frequently consulted the *Krou Khmer*, prayed to the spirits of the ancestors, and offered food to the spirits as the mediums instructed.

More time passed.

By the time she was six years old, Siew Ly could sit but not very stably; she could speak but the people outside her family could not understand her; and she could not walk. The parents were quite hopeless; they stopped consulting the *Krou Khmer* and praying to the ancestral spirits. They turned back to their business.

Even though Siew Ly could not walk, her body continued to grow as the years passed. Now she is twelve. She often shuffles to the stairs and asks others to carry her up or down and put her either into the hammock under the house or into the swing in front of the house. Because her arms and legs are uncooperative, she often falls from the hammock or swing. But this experience provides a secret opportunity for her to stand up by herself. By the time she is thirteen, she can stand up in misery by herself, but she still cannot step.

One day God blessed Siew Ly. An old lady who is a traditional medical practitioner saw Siew Ly and asked that her parents bring her in for treatment. The parents did not expect any results, but decided to try anyway. So they brought Siew Ly to the lady's house. She did not allow anybody to stay with Siew Ly. While her parents were returning

home, their tears dropped out of pity because their child had to live with an old lady in a small cottage.

The old lady tied a bamboo pole to a betel nut tree to serve as a tightrope. The old lady asked Siew Ly to do exercises. The exercises consisted of Siew Ly grabbing this tightrope pole to help her stand up. Even though Siew Ly fell many times the lady didn't care. Siew Ly had to try very hard to hang on and walk along the tightrope. In addition to this exercise, Siew Ly had to do housework such as throwing rice to the chickens, washing up, cooking rice, and pulling out weeds.

Because she lived far away for six months, Siew Ly missed her home, good food, the family camaraderie when they were all together, and the warmth and tender care from her parents and grandparents. She dreamed that she was home now—swinging, watching television, or listening to music. But she also enjoyed observing real nature at the old lady's house. She could see the cows and buffalos, and watch the farmers planting rice, because sometimes the old lady hitched her cow to a cart and took Siew Ly with her to the field. At Phnom Penh with her parents she enjoyed many nice, good things. But she never went out of the house gate, and when guests visited she hid herself in her room.

In her first month at the old lady's house, Siew Ly's parents went to see her every week. During the second month, relatives or grandparents visited her on two or three occasions. This change maybe took place because Siew Ly's family trusted this old lady. Or maybe they were very busy with their business; we don't know.

During the sixth month, Siew Ly significantly developed her movements. She could stand up more quickly than before, and could step four or five steps without hanging onto the tightrope. The old lady's treatment method was a great success. Everybody was very happy. They thought that God had given the light of life to Siew Ly.

Dear Reader, who among these people do you think was the most happy?

The family decided to bring Siew Ly back home. Now Siew Ly was like a student who had just graduated from university. She remembered the instruction of the old lady and her intensive training for six months. Now she is fourteen years old, and can help with a lot

of the housework. Everything she did, she did well. The plates and dishes that she washed were so bright you could see your face reflected from them as in a mirror. If she swept the house, even the ants could not escape.

Previously the older people in the family felt only pity for her because of her disabilities. But now they added a great heart of love and praise. Siew Ly had become a useful contributor to her family.

In 1998, God sent the Marist Mission of Australia to Cambodia. He charged this group to open a school for disabled children.

A golden opportunity for Siew Ly had arrived.

On 22 June 1998, the school opened. Among the forty-seven disabled students came Siew Ly. Her parents arrived with happy faces, and walked with Siew Ly to help her. She could not control her movements, and so could only walk with difficulty. She didn't wear shoes, not because her family lacked the money, but because she couldn't wear them. At that time Siew Ly was fourteen years old, and was neither particularly fat nor thin. During her first half year there, Siew Ly developed very quickly.

During the first two days of school, we did not study letters. We let the children play, talk about their families, and introduce themselves to one another. We explained about school policies, uniforms, and the reasons why this school was opened. Siew Ly was smiling the whole time.

Among the forty-seven students, five could hardly hold pen or chalk. Siew Ly was among those five. One student wrote with his leg. Another could not write in the notebook, so we got a big board for him to write on with chalk. A few months later, these students could write in their notebooks by using extra large pens. Their letters were quite big and not so good, but we were very happy and we could read them.

As for Siew Ly, her letters were small and neatly written. Siew Ly was very diligent; she did all her homework carefully. Every day Siew Ly had to do exercises for one hour in order to stretch the ligaments of the arms, legs, and hips, and to help her try to walk a straight line. She always tried so hard to do it, and never complained or came late. At school Siew Ly was always happy, and one day she

expressed her feeling that, "I don't want the weekend to come; at home I miss the class so much."

One thing that made her very happy is the teacher taught her how to wear shoes. She chose sports shoes. First we taught her how to wear socks, and then we guided her to wear shoes, but just during class. The first week we taught and helped her, but the second week she put them on by herself. When she knew very well how to put them on, we allowed her to walk while wearing the shoes. Her classmates encouraged and motivated her in many ways when they saw her walking with shoes. She was a little bit shy at first because she had never walked with shoes for fourteen years, but she was extremely happy. This was another success in her life.

One day the teacher brought the students to the Praseth Mountain. After lunch most of the students sat and talked together under the tree. But Siew Ly was not among them; she had wandered off alone. The teacher began searching for her because she was afraid of losing Siew Ly, but Siew Ly said, "I'm very happy, teacher. I have never before walked as well as today. I'm sorry I made you worry about me." The teacher was not angry but very proud of her student. The teacher held Siew Ly and said, "I'm afraid that you are going to fall by yourself." Siew Ly replied, "Never mind, teacher. If I fall I can get up by myself."

The school at which Siew Ly studied is named "Lavala." She studied there for two years. She could read, write, and calculate. She is a very clever student, responsible, and never made any difficulties to her friends and teachers. When she was writing, she needed to spend a lot of time on it because her arms were always subject to spasms. Her struggle in writing and doing the exercises made her a very good example to those who didn't have to work as hard as she did.

In the year 2000, Siew Ly contracted typhoid fever and could not attend school. But when she recovered her family did not allow her to return, and we do not know why. The teacher went to visit, and found her thinner than before. She always sleeps on the mat, not eating, not speaking. Her grandmother said that she could not sleep at night.

When she met the teacher, she smiled with a sour face. She looked at the teacher for a while and turned away, and then she was crying. The teacher said nothing, just fondled the student's arms and said goodbye.

We have not seen Siew Ly for about two years. We miss her. Does she miss us or not?

May God bless and give hope to her!



*Siew Ly and her former teacher Soun Neang*

## Conclusion

Disabilities are very hard for those who have them. But we must not think that disabled people cannot be useful. We can see from Siew Ly's example that she could learn to study, write, walk, and work in the house as do people without disabilities. Usually the parents of disabled children always want them to walk or do things as well as others. Please look at the people who can walk and speak well but do not have the strength of character that Siew Ly has, because they neither had to struggle nor exert the serious effort the Siew Ly did to develop their abilities.

There are three conditions to help in ability development:

1- A brave heart that struggles to win over all difficulties.
2- A stubborn heart that rejects the old clichés that say, "Disabled persons are worthless," or "Disabled persons can do nothing."
3- Support and encouragement from friends, parents, and organizations.

Siew Ly's case has taught us that doing proper exercises is very useful in restoring body movement.

Siew Ly is not like the slogan that says, "*Que será será.*"

God has opened the door for her and blessed her. She has received God's blessing and obeyed Him with all of her heart.